
ត្រអាឡស់

កាលដើមដំបូងឡើយមានតែព្រះជាម្ចាស់ ទ្រង់គង់នៅតាំងតែពីដំបូងមករហូតអស់កល្បរៀងទៅ ។ ទ្រង់គ្មានដើមគ្មានចុង ទ្រង់ជាវិញ្ញាណដែលយើងមិនអាចមើលឃើញឬប៉ះពាល់បានឡើយ ទ្រង់មានគ្រប់រិទ្ធចេស្តាអាចធ្វើអ្វីៗគ្រប់បែបយ៉ាងបាន គ្មានអ្វីដែលទ្រង់ធ្វើមិនកើតសោះឡើយ ទ្រង់គង់នៅគ្រប់ទីកន្លែង ទ្រង់ជ្រាបដឹងពីអ្វីៗសព្វបែបយ៉ាងទាំងអស់ ទ្រង់គ្រប់លក្ខណ៍មិនដែលមានកំហុសសោះឡើយ ទ្រង់សុចរិតយុត្តិធម៌ និងស្មោះត្រង់ជាទីបំផុតហើយមិនដែលប្រែប្រួលសោះឡើយ ។





ព្រះជាម្ចាស់បានបង្កើតពួកទេវតា ទេវតាទាំងអស់ដែលព្រះបានបង្កើតមកសុទ្ធតែល្អកាលដើមឡើយ គេគោរពកោតខ្លាច និង ស្ដាប់ បង្គាប់ព្រះជាម្ចាស់ណាស់ តែក្រោយមកមានមហាទេវតាមួយឈ្មោះសាតាំងវាបានក្បត់នឹងព្រះជាម្ចាស់ព្រោះ វាចង់ធ្វើធំស្មើនឹងទ្រង់ ។ វាឈប់ស្ដាប់បង្គាប់ទ្រង់ ហើយដើរបំផុសបំផុលទេវតាឯទៀតអោយឈប់ ស្ដាប់បង្គាប់ព្រះជាម្ចាស់ដូចវាដែរ ហើយអោយស្ដាប់បង្គាប់វាវិញ ។ ការដែលវាមិនស្ដាប់បង្គាប់ព្រះជាម្ចាស់នាំអោយវាមានអំពើបាប ព្រះជាម្ចាស់ក៏បានទម្លាក់វាពីស្ថានសួគ៌មក ។



តើអ្នកណាខ្លះដែលព្រះជាម្ចាស់  បានទម្លាក់ពីឋានសួគ៌មក ?គឺទេវតាទាំងអស់ដែលស្ដាប់តាមមហាទេវតាឈ្មោះសាតាំងនេះ សព្វថ្ងៃនេះវាខំនាំយើងអោយធ្វើបាប ។



ក្រោយមកទៀតព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី របស់សព្វសារពើ សត្វគ្រប់ប្រភេទ និងមនុស្សដែលទ្រង់បានសូន្យពីដីមក អោយមានរូបរាងដូចជាទ្រង់ដែរ ហើយអោយមានអំណាចលើជីវិត ទាំងអស់នៅផែនដីនេះរួចទ្រង់អោយធ្វើសួនច្បារមួយឈ្មោះថាសួនច្បារអេដែន ហើយក៏ដាក់មនុស្សដែលទ្រង់បានសូន្យអោយនៅ ហើយទ្រង់ដាក់ឈ្មោះអោយគេថា អ័ដាម ។ ព្រះជាម្ចាស់ទ្រង់ ជ្រាប់ពីសេចក្តីត្រូវការរបស់អ័ដាម ទ្រង់បានធ្វើអោយគេដេកលក់ ហើយទ្រង់បានយកឆ្អឹងជំនីរគាត់មួយ មកហើយជប់អោយទៅជាស្រ្តីម្នាក់ហើយអ័ដាមបានដាក់ឈ្មោះថា អេវ៉ា ។ អ្នកទាំងពីរបាន រស់នៅយ៉ាងសុខសាន្តជាមួយព្រះជាម្ចាស់ ព្រះជាម្ចាស់បានហាម ផ្តាច់មិនអោយគេបរិភោគផ្លែដឹងខុសត្រូវឡើយក្រែងលោស្លាប់ មានន័យថាគេនឹងដាច់ចេញពីព្រះ ។





ថ្ងៃមួយ អារក្សសាតាំងដែលជាខ្មាំងសត្រូវនឹងព្រះជាម្ចាស់វាបានចូលក្នុងសួនច្បារអេដែន ក្នុងរូបរាងជាសត្វពស់ហើយល្បួងអេវ៉ាអោយបរិភោគផ្លែដឹងខុសត្រូវ ដោយចាញ់សេចក្តីល្បួងអារក្សសាតាំង អ័ដាមនិងអេវ៉ាបានធ្វើខុសនឹងបញ្ញត្តរបស់ព្រះជាម្ចាស់ហើយធ្វើតាមអារក្សវិញដោយការមិនស្តាប់បង្គាប់ព្រះជាម្ចាស់អ្នកទាំងពីក៏បានទទួលធ្លាក់ទៅក្នុងអំពើបាប ។





ព្រះជាម្ចាស់បានដេញគេចេញពីសួនច្បារ អេដែន គេបានដាច់ចេញពីព្រះ ជីវិតរបស់គេទៅជាពិបាក កាលដើមឡើយគេស្តាប់បង្គាប់ព្រះ តែឥឡូវនេះ គេស្តាប់បង្គាប់តាមអារក្សសាតាំងវិញ គេក្លាយខ្លួនទៅជាមនុស្សកុហក លួច ប្លន់ កេងប្រវ័ញ្ចជាដើម ។





តើមនុស្សប៉ុន្មាននាក់ដែលធ្លាក់ទៅក្នុងអំពើបាប? ដោយអ័ដាមនិងអេវ៉ាដែលជាឪពុកម្តាយដើមរបស់យើងជាអ្នកបំរើនៃអារក្សសាតាំងនាំអោយយើងទាំងអស់គ្នាក៏ក្លាយទៅជាអ្នកបំរើអារក្សសាតាំងដែរ សូម្បីតែកូនក្មេងដែលមិនទាន់ដឹងក្តីក៏ស្តាប់បង្គាប់តាមអារក្សសាតាំងដែរ ។ដើម្បីបានយល់ច្បាស់ចូរអ្នកមើលរូបភាពនៅសន្លឹកទី៧នេះចុះ អ្នកនឹងឃើញច្រវាក់ដែលប្រទាក់បន្តគ្នាពីម្នាក់ទៅម្នាក់គឺជានិមិត្តរូបពីអំពើបាបដែលបានបន្តពីម្នាក់ទៅម្នាក់ រហូតដល់យើងសព្វថ្ងៃនេះក៏មានបាបដែរ គឺជានិស្ស័យបាបដែលបន្តពីឪពុកម្តាយដើមយើងមក គ្មានអ្នកណាអាចជៀសផុតបានឡើយ ។





ព្រះជាម្ចាស់នៅតែអាណិតស្រលាញ់មនុស្សលោក យ៉ាងខ្លាំងទ្រង់បានកើតជាមនុស្សគឺ ថាព្រះយេស៊ូវបានយាងមកចាប់កំណើត នឹងស្ត្រីព្រហ្មចារីម្នាក់ ឈ្មោះម៉ារាដែលជាគូរដណ្តឹងរបស់យ៉ូសែប ។ ទ្រង់បានប្រសូត្រមកមានភាពជាមនុស្ស១00% ហើយក៏មានភាពជាព្រះ១00% ដែរ ទ្រង់បានយាងមកដើម្បីបង្ហាញអោយយើង ស្គាល់របៀបរស់នៅដោយមិនប្រព្រឹត្តអំពើបាប ទ្រង់បានប្រសូត្រនៅក្នុងទីកន្លែងដ៏សែនថោកទាបគឺដើម្បីអោយមនុស្សគ្រប់ស្រទាប់វណ្ណៈបានមកដល់ឯទ្រង់បានគ្រប់គ្នាអោយតែមានចិត្តចង់ចូលទៅឯទ្រង់ ចាប់តាំងពីវណ្ណៈខ្ពស់បំផុតដូចជាស្តេចរហូតដល់វណ្ណៈ ទាបបំផុត ដូចជាអ្នកក្រសុំទានជាដើម ។



នៅក្នុងព្រះជន្មបាន៣៣ព្រះវស្សា ទ្រង់សុគតព្រះរាជហឫទ័យសុគត នៅលើឈើឆ្កាង គេបានវាយធ្វើបាបទ្រង់យ៉ាងវេទនាជាទីបំផុត គេបានត្មេះតេះដៀលទ្រង់សព្វបែបយ៉ាងតែទ្រង់ឥតមានត្អូញត្អែរឬថ្ងូរឡើយគឺទ្រង់អត់ធ្មត់ជានិច្ច ។ យើងបានដឹងហើយថាទ្រង់គឺជាព្រះ ទ្រង់មិនដែលធ្វើបាបសោះ ទ្រង់បានជ្រាបដឹងពីហេតុការណ៍គ្រប់បែបយ៉ាងដែលនឹងកើតឡើងជាមុន ហើយទ្រង់មានគ្រប់ឫទ្ធិចេស្តា ហេតុអ្វីបានជាទ្រង់មិនរត់គេច ឬ បំរះអោយរួចពីចំណងនេះទៅ ? ហេតុអ្វីបានជាទ្រង់ស៊ូទ្រាំម្ល៉េះ ? គឺដើម្បីជួយសង្គ្រោះយើងរាល់គ្នាអោយរួចពីបាបដោយសារព្រះលោហិតរបស់ទ្រង់ បានសំអាតបាបយើង ព្រះជាម្ចាស់ទ្រង់យុត្តិធម៌បានជាទ្រង់វិនិច្ឆ័យបាប មានតែព្រះយេស៊ូវមួយអង្គគត់ដែលមិនដែលធ្វើបាបទាល់តែសោះ ហេតុនេះហើយបានជាទ្រង់ជួយយើងបាន ។ យើងរាល់គ្នាគួរតែចងចាំពីព្រឹត្តិការណ៍ដ៏អស្ចារ្យនេះមិនអាចបំភ្លេចបានឡើយ ។



ពេលទ្រង់សុគតគេបានយកព្រះសពទ្រង់ទៅបញ្ចុះក្នុង
ផ្នូរដោយយកផ្ទាំងថ្មយ៉ាងធំបិទជិត ។

ទ្រង់សុគតតែបីថ្ងៃទ្រង់រស់ឡើងវិញហើយ  នេះជា
ភស្តុតាងថាទ្រង់បានឈ្នះអារក្សសាតាំងមែន ។

សព្វថ្ងៃនេះទ្រង់គង់នៅជាមួយនឹងអស់អ្នកណាដែល
ទទួលនិងជឿដល់ទ្រង់ ។



បើយើងចង់អោយព្រះយេស៊ូវអត់ទោសបាបអោយ
យើងហើយបើយើងចង់ក្លាយទៅជាកូនព្រះតើយើងត្រូវ
ធ្វើយ៉ាងដូចម្តេច?យើងត្រូវធ្វើដូចជាមនុស្សក្នុងរូបភាព
នេះដែរគឺ យើងត្រូវចូលមកឯព្រះយេស៊ូវទាំងជាប់
ចំណងនៃអំពើបាបយើងត្រូវមកលុតជង្គង់នៅ ចំពោះ
ទ្រង់ សូមអោយទ្រង់អត់ទោសបាបអោយ យើងដោយ
ចិត្តក្តុកក្តួល និង នឹកស្តាយពីកំហុសដែលយើងបាន
ប្រព្រឹត្ត យើងមិនត្រូវអៀនខ្មាស់ឡើយ យើងត្រូវបាន
សារភាពហើយសូមអោយទ្រង់ជួយសំអាតយើងអោយ
បានស្អាតអំពីបាប ដោយសារព្រះលោហិតរបស់ទ្រង់
យើងត្រូវជឿថាទ្រង់រស់ ឡើងវិញហើយយើងត្រូវ
ថ្វាយ ចិត្តគំនិត និងជីវិត របស់យើងដល់ព្រះយេស៊ូវ
ដោយឥតស្តាយក្រោយ ឡើយ ។





ព្រះយេស៊ូវនឹងផ្ដាច់ចំណងនៃអំពើបាបរបស់យើងហើយ យើងនឹងមានសេរីភាព     អារក្សសាតាំងមិនអាចគ្រប់គ្រងលើជីវិតយើងទៀតឡើយ ។



យើងត្រូវប្រែចិត្តឈប់ដើរតាមផ្លូវរបស់សាតាំងទៀត
កាលពីមុនយើងធ្លាប់កុហក់ ធ្លាប់លួច ធ្លាប់ប្លន់ ។ល ។
ឥឡូវនេះព្រះយេស៊ូវនឹងជួយយើងអោយឈប់
ប្រព្រឹត្តដូចមុនទៀត ឈប់ដើរផ្លូវពីរហើយដើរតាម
ផ្លូវដ៏ល្អតែមួយគត់ គឺដើរតាមព្រះយេស៊ូវគ្រីស្ទ
យើងនឹងប្រព្រឹត្តតែការល្អគឺសុចរិតយុត្តិធម៌ និង
ស្មោះត្រង់ជាប់ជានិច្ច ។
បើយើងធ្វើខុសយើងត្រូវសូមទោសព្រះអង្គភ្លាម
ទ្រង់នឹងអត់ទោសបាបអោយយើង ជីវិតរបស់
យើងនឹងបានពោរពេញទៅដោយសេចក្ដីអំណរនិង
សេចក្ដីសុខសាន្ត ។





តើអ្វីខ្លះដែលយើងអ្នកជឿព្រះយេស៊ូវត្រូវលះបង់?

-យើងត្រូវឈប់រកគ្រូទាយដោយមើលបាតដៃ ឬមើលសន្លឹកបៀរ ។ល ។

-យើងត្រូវឈប់ពាក់ខ្សែកឬខ្សែចង្កេះដែលមានកថាបញ្ចុះដោយមន្តអាគមន៏ព្រមទាំងឈប់រកគ្រូទាយឬគ្រូមន្តអាគមន៏ទាំងអស់ ។

-យើងឈប់ដោតធូបនៅខ្ទមអ្នកតាឬថ្វាយបង្គំរូបចំលាក់ផ្សេងៗទៀតហើយ ព្រោះរបៀបនេះគឺជាការហៅវិញ្ញាណអាក្រក់អោយវាមកគ្រប់គ្រងក្នុងជីវិតរបស់យើង ។



តើអ្វីខ្លះដែលយើងអ្នកជឿព្រះយេស៊ូវត្រូវធ្វើ ?

-យើងត្រូវថ្វាយទ្រព្យសម្បត្តិ ប្ដី កូន ប្រពន្ធ ដល់ព្រះយេស៊ូវគ្រីស្ទ កុំអោយភ័យខ្លាចព្រះអង្គយករបស់យើង ឬធ្វើអោយយើងរងគ្រោះថ្នាក់ឡើយ មានមនុស្សជាច្រើនយល់ច្រលំ គេមិនហ៊ានថ្វាយប្ដីកូនឬប្រពន្ធដល់ព្រះជាម្ចាស់ឡើយ ដោយភ័យខ្លាចក្រែងទ្រង់ធ្វើអោយគេវិនាសឬធ្វើអោយគេស្លាប់ នេះជាគំនិតខុសឆ្គងមែនទែន ព្រោះព្រះនៃយើងទ្រង់ល ទ្រង់មិនដែលធ្វើអាក្រក់នឹងយើងឡើយ

-យើងត្រូវថ្វាយពេលវេលាដល់ព្រះ គឺត្រូវប្រើពេលវេលាដើម្បីអានគម្ពីរ អធិស្ឋាន ប្រជុំរៀនសូត្រជាមួយគ្រីស្ទានឯទៀត ទៅសួរសុខទុក្ខស្ត្រីមេម៉ាយ ក្មេងកំព្រា អ្នកកំសត់ ទុរគត ។ល ។

-យើងត្រូវថ្វាយចិត្តដល់ព្រះជាម្ចាស់ គឺយើងមិនជឿព្រះឯទៀត ឬវិញ្ញាណផ្សេងៗក្រៅពីព្រះយេស៊ូវឡើយ ព្រោះទ្រង់ស្រលាញ់យើងយកព្រះទ័យទុកដាក់នឹងយើង គ្មានអ្នកណាល្អដូចជាទ្រង់ឡើយ ។ និយាយសង្ខេបគឺថា យើងស្រលាញ់ព្រះជាម្ចាស់អោយអស់អំពីចិត្ត ហើយស្រលាញ់អ្នកជិតខាងឱ្យដូចជាខ្លួនឯង ។





ពេលយើងស្លាប់ទៅយើងមិនព្រួយបារម្ភឬភ័យ

ខ្លាចឡើយព្រោះយើងដឹងថា យើងមានកន្លែងមួយ

ដែលព្រះជាម្ចាស់បានរៀបចំសំរាប់យើងគឺឋានសួគ៌ ។



ឱព្រះយេស៊ូវអើយ ខ្ញុំជឿជាក់ថាទ្រង់គឺជាព្រះដ៏ខ្ពស់បំផុត ហើយទ្រង់បានសុគតនៅលើឈើឆ្កាង ដើម្បីទទួលកម្មរបស់ខ្ញុំរួចទ្រង់រស់ពីសុគត ឡើងវិញ ។ ខ្ញុំដឹងថាខ្ញុំជាមនុស្សដែលមានបាបតាំងពី កំណើតមក ខ្ញុំបានធ្វើខុសនឹងបញ្ញត្តទ្រង់ ខ្ញុំបានរួចពីបាបនិងចង់រួចពីអំណាចនៃអារក្សសាតាំងក្នុងជីវិត ខ្ញុំសូមព្រះអង្គអត់ទោសនូវសេចក្តីកំហុសរបស់ខ្ញុំ សូមអោយខ្ញុំបានត្រឡប់ទៅជាកូនព្រះ ខ្ញុំព្រមដើរចេញពីអារក្សសាតាំងនិងការគោរពចំពោះវាគ្រប់បែបយ៉ាង ដោយអំណាចព្រះចេស្តារបស់ទ្រង់ សូមឱ្យខ្ញុំបានរស់នៅឱ្យបានសមរម្យជាកូនព្រះរហូតដល់អវសានត្តនៃជីវិតខ្ញុំ អរគុណព្រះជាម្ចាស់ដែលទ្រង់បានរៀបចំកន្លែងសំរាបខ្ញុំនៅស្ថានសួគ៌ ហើយខ្ញុំនឹងរស់នៅជាមួយទ្រង់រហូតអស់កល្បជានិច្ច ។

សៀវភៅនេះលោកអ្នកបានទទួលមកពី :

ឈ្មោះព្រះវិហារ ..........................................

អាស័យដ្ឋាន ..........................................

ទូរស័ព្ទលេខ ..........................................

សូមអញ្ជើញមកជួបនឹងខ្ញុំ ដើម្បីរៀនបន្ថែមទៀតអំពីជីវិតថ្មីដោយសារព្រះយេស៊ូវគ្រីស្ទ ។

“God” — Cambodian

Published By Foursquare Missions Press ©2004